**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.គសហវ

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០២០

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ÷** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ផ្តល់ប្រាក់ឧបត្ថម្ភក្នុងការបើកវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអប់រំចាប់ពីឆ្នាំ២០២០ តទៅ ។

**យោង÷** លិខិតលេខ៧១០១ អយក.ហវ ចុះថ្ងៃទី១៧-១២-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជ្រាបថា ក្នុងគោលបំណងបង្កើនសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ឱ្យមានលទ្ធភាពក្នុងការគ្រប់គ្រងនិងដឹកនាំប្រកបដោយភាពទទួលខុសត្រូវ និងមានមនសិការវិជ្ជាជីវៈខ្ពស់ និងដោយមើលឃើញពីតម្រូវការ និងភាពចាំបាច់ក្នុងការកសាងសមត្ថភាពបន្ថែមជូនបុគ្គលិកអប់រំឱ្យទាន់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព និងស្របជាមួយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងកម្មវិធីកែទម្រង់វិស័យអប់រំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យនិងឯកភាពដូចខាងក្រោម ÷

## I. ឥណទានថវិកា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឯកភាពជាគោលការណ៍ឧបត្ថម្ភសម្រាប់បើកវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអប់រំចាប់ពីឆ្នាំ២០២០ តទៅ ។

## II. មុខសញ្ញា និងគោលរបបសម្រាប់ចំណាយ

| ល.រ | បរិយាយ | ឯកតា | ថ្លៃឯកតា |
|---|---|---|---|
| ១ | ការធ្វើដំណើរ ស្នាក់នៅ និងហូបចុករបស់សាស្ត្រាចារ្យបរទេស | | |
| | - សំបុត្រយន្តហោះទៅ-មក | | អត្រាអគ្គ.គោលនយោបាយ គសហវ |
| | - ការស្នាក់នៅ | ១ យប់ | ២០០ ០០០៛០០ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

| | | | |
|---|---|---|---|
| | - អាហារ | ១ ថ្ងៃ | ១២០ ០០០៛០០ |
| ២ | ការធ្វើដំណើរ ស្នាក់នៅ និងហូបចុករបស់វាគ្មិនបរទេស | | |
| | សំបុត្រយន្តហោះទៅ-មក | | អត្រាអគ្គ.គោលនយោបាយ កសហវ |
| | - ការស្នាក់នៅ | ១ យប់ | ២០០ ០០០៛០០ |
| | - អាហារ | ១ ថ្ងៃ | ១២០ ០០០៛០០ |
| ៣ | ប្រាក់ម៉ោងបង្រៀនសម្រាប់សាស្ត្រាចារ្យ គ្រូបង្រៀន និងវាគ្មិន | | |
| | - សាស្ត្រាចារ្យ | ១ ម៉ោង | ១៥០ ០០០៛០០ |
| | - សាស្ត្រាចារ្យរង | ១ ម៉ោង | ១២០ ០០០៛០០ |
| | - សាស្ត្រាចារ្យជំនួយ | ១ ម៉ោង | ១០០ ០០០៛០០ |
| | - គ្រូបង្រៀន | ១ ម៉ោង | ៨០ ០០០៛០០ |
| | - វាគ្មិន | ១ ម៉ោង | ២០០ ០០០៛០០ |
| ៤ | ការដឹកនាំនិក្ខេបបទ | | |
| | - គ្រូដឹកនាំបង្គោល | ១ នាក់ | ៤ ០០០ ០០០៛០០ |
| | - គ្រូដឹកនាំបង្គោលរង | ១ នាក់ | ៣ ០០០ ០០០៛០០ |
| ៥ | ការការពារនិក្ខេបបទបញ្ចប់ | ១ នាក់ | ៤០០ ០០០៛០០ |

## III. ការគ្រោងនិងការកត់ត្រា

**ក.** ចំពោះចំណាយដំណើរការរៀបចំថ្នាក់បណ្ឌិត ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោង និងកត់ត្រាក្នុងអនុគណនីផ្សេងៗទៅតាមមុខសញ្ញាចំណាយជាក់ស្តែងអនុលោមតាមប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ខ.** ចំពោះចំណាយប្រាក់ម៉ោងបង្រៀន, សោហ៊ុយធ្វើដំណើរ ហូបចុក និងស្នាក់នៅ របស់សាស្ត្រាចារ្យបរទេស និងសាស្ត្រាចារ្យកម្ពុជាដែលមិនមែនជាមន្ត្រីរាជការ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោង និងកត់ត្រាក្នុងអនុគណនី ៦១០៤១ (សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស) ។

**គ.** ចំពោះចំណាយដឹកនាំនិក្ខេបបទ និងការការពារនិក្ខេបបទ ត្រូវកត់ត្រាចូលក្នុងអនុគណនី ៦២០៦១ (ចំណាយលើការប្រឡង-ប្រឡងប្រជែង) ។

## IV. ការគ្រោងឥណទានថវិកាឆ្នាំ២០២០

អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំនិយ័តភាពឥណទានថវិកាពីអនុគណនី ដែលបានគ្រោងក្នុងឆ្នាំ ២០២០ មកអនុគណនីខាងលើនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាពិនិត្យ និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**